**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៥៤ អនក្រ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួងបង្រ្កាបបទល្មើស ភាពយន្ត និងវីដេអូ ក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈ ភាពយន្ត និងវីដេអូ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីត្រួតពិនិត្យ និងចាត់វិធានការបង្រ្កាប ការបញ្ចាំងវីដេអូអាសអាភាស ការលក់ ឬជួលស្នាដៃភាពយន្ត និងស្នាដៃវីដេអូអាសអាភាសគ្មានទិដ្ឋាការគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២. ឯកឧត្តម | **ឈឹម ជួន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. លោកជំទាវ | **ដាំ ដារីនី** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិកា |
| ៤. លោកជំទាវ | **ហ៊ូ សាមិត្ត** | រដ្ឋលេខាធិការកិច្ចការនារី | សមាជិកា |
| ៥. ឯកឧត្តម | **គង់ កន្ធារ៉ា** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៦. លោកជំទាវ | **ខៀវ សុផានី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៧. ឯកឧត្តម | **តុប សុភ័គ** | អនុរដ្ឋលេខាក្រសួងទេសចរណ៍ | សមាជិក |
| ៨. ឯកឧត្តម | **អ៊ីវ ផល្លី** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |

**ប្រការ ២.-**

គណៈកម្មាធិការនេះមានភារកិច្ច ៖

- តាមដាន និងពិនិត្យការអនុវត្តន៍អនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការគ្រប់គ្រង ត្រួតពិនិត្យ សិល្បៈ ភាពយន្ត និងវីដេអូ។
- សហការជាមួយគណៈកម្មការចំរុះ និងអាជ្ញាធរដែនដី គ្រប់ខេត្ត-ក្រុង ក្នុងការអនុវត្តន៍អនុក្រឹត្យ សារាចរ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យភាពយន្ត វីដេអូ។
- តាមដាន ត្រួតពិនិត្យ ដើម្បីកែលំអរ ពង្រឹង និងពង្រីកការងារទប់ស្កាត់បង្ក្រាបព្រមទាំងបំបាត់ការធ្វើអាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ ខារ៉ាអូខេ អណាធិបតេយ្យទូទាំងប្រទេស។
- ចូលពិនិត្យរោងបញ្ចាំងភាពយន្ត រោងបញ្ចាំងវីដេអូ កន្លែងធ្វើអាជីវកម្មខារ៉ាអូខេ តាមស្ថានីយ៍ទូរទស្សន៍ និងទូរទស្សន៍ខ្សែកាបទូទាំងប្រទេសក្នុងការចាក់បញ្ចាំងផលិតផលភាពយន្ត វីដេអូគ្រប់ប្រភេទ។
- ត្រួតពិនិត្យកន្លែងអាជីវកម្ម ជួល លក់ ខ្សែភាពយន្ត កាសែ្សតវីដេអូ ឡាស៊ែរឌីស ស៊ីឌីវីដេអូ ឌីវីឌី គ្រប់ប្រភេទលើការដាក់តាំងជួល លក់ នៅតាមទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា។
- ធ្វើកំណត់ហេតុ រៀបចំសំណុំរឿងពាក់ព័ន្ធបទល្មើស និងរាយការណ៍ជូនគណៈរដ្ឋមន្ត្រី។

**ប្រការ៣.-**

សមាជិក សមាជិកាគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ៤.-**

គណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្ត និងវីដេអូ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៥-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ៥ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល ៖__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- គ្រប់រាជធានី-ខេត្ត